# ការណែនាំ

ស្តង់ដារពិការភាព
សំរាប់ការអប់រំ



# ចាប់ផ្តើម:
# ពិការភាពនិងការអប់រំ

ធនធាននេះគឺសំរាប់មាតាបិតានិងអ្នកថែរក្សាដែល
ថ្មីថ្មោងនឹងពិការភាពនិងប្រព័ន្ធអប់រំអូស្ត្រាលី។

ធនធាននេះត្រូវបានបង្កើតរួមគ្នាដោយសិស្សនិងក្មេងដែលមានពិការភាព និងមាតាបិតា និងអ្នកថែរក្សារបស់គេ។

## អំពីធនធាននេះ

ធនធាននេះត្រូវបានទទួលមូលនិធិពីរដ្ឋាភិបាលអូស្ត្រាលី។ វាត្រូវបានបង្កើតដោយសិស្សនិងក្មេងដែលមានពិការភាពនិងមាតាបិតានិងអ្នកថែរក្សារបស់គេ រួមនឹងជំនួយពី**កុមារនិងយុវជនដែលមានពិការភាពអូស្ត្រាលី** (Children and Young People with Disability Australia - CYDA) ហើយនិង**សម្ព័ន្ធពិការភាពនៃជាតិសាសន៍ប្រចាំជាតិ** (National Ethnic Disability Alliance -NEDA)។

រដ្ឋាភិបាលអូស្ត្រាលីទទួលស្គាល់ម្ចាស់ទឹកដីដើមនិងអ្នកថែរក្សាស្រុកទូទាំងប្រទេសអូស្ត្រាលី។ យើងទទួលស្គាល់ដល់ទំនាក់ទំនងដ៏និរន្តន៍ជាមួយដី ទឹក និងសហគមន៍របស់គេ។ យើងសូមគោរពដល់ពួកគេនិងដល់ពួកចាស់ទុំពីអតីតកាលនិងបច្ចុប្បន្នកាល។ យើងសូមគោរពដល់ការអនុវត្តផ្នែកវប្បធម៌ ព្រលឹងវិញ្ញាណ និងការអប់រំនៃជនអាបូរិជិនី និងពួកកោះTorres Straight.

## កំណត់សំគាត់ពីភាសា

ធនធាននេះប្រើភាសាបុគ្គលមុន (ឧ. សិស្សដែលមានពិការភាព)។ ប៉ុន្តែវិធីនេះមិនសមនឹងមនុស្សគ្រប់រូប ហើយមនុស្សជាច្រើនចូលចិត្តភាសាអត្តសញ្ញាណមុន (ឧ. សិស្សពិការ)។

វាសំរេចទៅលើបុគ្គលម្នាក់ៗ ដែលគេជ្រើសរើសសំគាល់ខ្លួនដោយរបៀបណានោះ។ យើងសូមលើកទឹកចិត្តអ្នកអោយសួរគេថាគេចូលចិត្តអ្វី។ យើងក៏ទទួលស្គាល់ប្រវត្តិសាស្ត្រដ៏ជ្រាលជ្រៅដែលនៅពីក្រោយពាក្យទាំងនេះ ដែរ។

យើងប្រើពាក្យ 'ស្ថាប័នអប់រំ' និង 'សាលា ឬមជ្ឈមណ្ឌល' ក្នុងន័យតែមួយក្នុងធនធាននេះ។ ពាក្យទាំងពីរមានន័យថាជាកន្លែងដែលកូនអ្នកទទួលការអប់រំ។

ធនធាននេះសំរាប់មាតាបិតានិងអ្នកថែរក្សា។ យើងប្រើពាក្យ 'កូនរបស់អ្នក' គឺមានន័យថាកូនណាដែលអ្នករ៉ាប់ទទួលខុសត្រូវ។

## ធនធានបន្ថែម

នេះគឺផ្នែកមួយនៃធនធានមួយក្រុម។ អ្នកអាចរកឃើញនៅក្នុងវែបសៃត៍នៃក្រសួងអប់រំ ឬដោយស្កេនកូដ QR.

ស្កេនកូដ QR

ធនធាននេះក៏មាននៅក្នុង Easy Read, Auslan និងភាសាផ្សេងៗមួយចំនួនទៀត។ អ្នកអាចចូលមើលសំណេរទាំងនោះនៅវែបសៃត៍ Australian Government Department of Education ឬ ដោយស្កេនកូដ QR.

***កំណត់សំគាល់មាតិកា:*** *ធនធាននេះនិយាយពីការរើសអើងនិងការប្រកាន់។ មានឧទាហរណ៍ពីគំនិត និងភាសាអវិជ្ជមាន។ សូមទូរស័ព្ទមក Lifeline តាមលេខ **13 11 14** ឬផ្ញើសារមកលេខ **0477 13 11 14** សំរាប់ការជួយគាំទ្រ។*

## ការណែនាំនេះសំរាប់អ្នកណា

ការណែនាំនេះគឺសំរាប់អ្នកបើអ្នករ៉ាប់ទទួលខុសត្រូវលើក្មេងណាម្នាក់ដែលមានពិការភាព។ អ្នកប្រហែលជាមាតាបិតា អាណាព្យាបាល ឬអ្នកថែរក្សា។

## ការណែនាំនេះសំរាប់អ្វី

ការណែនាំនេះគឺសំរាប់ជួយអោយអ្នកចាប់ផ្តើម:

- រៀនអំពីសិទ្ធិទាំងឡាយនៃការអប់រំកូនអ្នក
- គិតអំពីជំរើសអប់រំរបស់កូនអ្នក។

## ការណែនាំនេះថ្លែងពីអ្វីខ្លះ

ការណែនាំនេះនិយាយអំពី:


- ពិការភាពមានន័យអ្វីខ្លះ (ទ. 1)
- ឥរិយាបថដល់ពិការភាព (ទ. 4)
- ជំរើសអប់រំរបស់កូនអ្នក (ទ. 6)
- ពេលកូនអ្នកចុះឈ្មោះរៀនហើយ (ទ. 9)
- គោលដៅសំរាប់ការអប់រំកូនរបស់អ្នក(ទ. 14)
- កន្លែងទទួលជំនួយគាំទ្រនិងព័ត៌មាន (ទ. 14)


## ពិការភាពមានន័យអ្វីខ្លះ

ដូចជាបណ្តាជនខុសគ្នាយ៉ាងណា ពិការភាពក៏ផ្សេកគ្នាយ៉ាងនោះដែរ។ ម្នាក់ៗមានគំនិតខុសគ្នាថាវាជាអ្វី។ អ្នកប្រហែលជាមិនប្រាកដថាបទពិសោធន៍នៃកូនអ្នករាប់ថាជាពិការភាពទេ។ គ្រូបង្រៀនឬគ្រូពេទ្យរបស់គាត់អាចប្រើពាក្យដូចជា:

- លក្ខណៈវេជ្ជសាស្ត្រ ឬជំងឺ
- សេចក្តីត្រូវការជំនួយបន្ថែម
- សមត្ថភាពខុសគ្នា
- ពិការ
- សេចក្តីត្រូវការប្រើប្រាស់អ្វីមួយ
- សេចក្តីត្រូវការពិសេស
- សេចក្តីត្រូវការកែសំរួល
- សេចក្តីត្រូវការការសំរប

ពាក្យទាំងនេះអាចសំដៅទៅលើពិការភាព។

កំណត់សំគាល់: ភាសាដែលយើងប្រើដើម្បីពិពណ៌នាខ្លួនយើងគឺជារឿងបុគ្គល ហើយស្រេចលើយើង។ ប៉ុន្តែពាក្យខ្លះក្នុងបញ្ជីនេះមានប្រវត្តិមិនល្អ។ យើងមិនយកមកប្រើទៀតទេក្នុងធនធាននេះ។

- ពាក្យថា ‘**ពិការភាព**’ គឺត្រូវបានប្រើនៅពេលយើងនិយាយពីសិទ្ធិ ច្បាប់ សេវាកម្ម និងជំនួយគាំទ្រ។

### និយមន័យ: ពិការភាព

ពិការភាពជាពាក្យមានន័យទូលំទូលាយ ហើយមាននិយាយពី:

- ការបាត់បង់នូវការប្រើរាងកាយឬគំនិតខ្លះៗឬបាត់បង់ទាំងស្រុង
- ការបាត់បង់ដល់ផ្នែករាងកាយណាមួយ ឬបាត់បង់ទាំងស្រុង
- វត្តមាននៃអង្គជាតិដែលបណ្តាលឬដែលអាចបណ្តាលអោយមានមេរោគឬជំងឺ (ឧ. HIV)
- វិបល្លាសនៃការរៀនសូត្រ
- វិបល្លាសនៃអាកប្បកិរិយា មនោសញ្ចេតនា ការគិតវិនិច្ឆ័យ ឬការប្រើគំនិត។

ពិការភាពមានប្រភេទខុសគ្នា:



**ទាក់ទងនឹងការប្រើគំនិត**

(ឧ. ដោនស៊ិនដ្រូម របួសខួរក្បាលបន្ទាប់ពីកើតមក)



**ទាក់ទងនឹងខួរក្បាល**

(ឧ. ជំងឺឆ្កួតជ្រូក អូទីស្សឹម)



**ទាក់ទងរាងកាយ**

(ឧ. ជំងឺរលាកសន្លាក់ ពិការខួរក្បាល)



**ការញ្ញាណ**

(ឧ. ខ្វាក់, ស្តាប់មិនឮ)



**សង្គម/មនោសញ្ចេតនា**

(ឧ. ជំងឺធ្លាក់ទឹកចិត្ត ជំងឺគិតហើយធ្វើដដែលៗ)

បទពិសោធន៍កូនរបស់អ្នកអាចត្រូវប្រភេទពិការភាពលើសពីមួយយ៉ាង។ គេក៏អាចមានលក្ខណៈឬពិការភាពលើសពីមួយក៏មាន។

## ច្បាប់រើសអើងពិការភាពអូស្ត្រាលី

សិស្សទាំងអស់ដែលមានពិការភាពក្នុងប្រទេសអូស្ត្រាលី ត្រូវបានការពារដោយ***ច្បាប់រើសអើងពិការភាព1992*** (DDA) និង***ស្តង់ដារពិការភាពសំរាប់ការអប់រំ2005*** (DSE)។ អ្នកផ្តល់ការអប់រំទាំងអស់ត្រូវអនុលោមតាម DDA និង DSE ។

### និយមន័យៈ ច្បាប់រើសអើងពិការភាព1992 (DDA)

ច្បាប់ DDA ជាច្បាប់មួយសំរាប់ជនគ្រប់រូបនៅប្រទេសអូស្ត្រាលី។
វាកាពារមិនអោយមានការរើសអើងដោយសារគេមានពិការភាព។

### និយមន័យៈ ស្តង់ដារពិការភាពសំរាប់ការអប់រំ 2005 (DSE)

ច្បាប់ DSE ជាច្បាប់មួយចំនួនដែលស្ថិតនៅក្រោម DDA។ ច្បាប់ទាំងនេះបញ្ជាក់កាតព្វកិច្ចរបស់អ្នកផ្តល់ការអប់រំ។
ច្បាប់ DSE ប្រាប់អ្នកផ្តល់ការអប់រំទាំងឡាយថាគេត្រូវធ្វើយ៉ាងណាដើម្បីគាំទ្រសិស្សដែលមានពិការភាព។

សិស្សមានពិការភាពត្រូវបានការពារដោយ DSE និង DDA នៅពេលគេទៅៈ

- សាលាដំបូង
- មត្តេយ្យសាលា
- សាលា
- សាលាជាន់ខ្ពស់
- សាលាអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

បច្ចុប្បន្ននេះច្បាប់ DSE មិនការពារដល់ការថែរក្សាក្មេងទេ ប៉ុន្តែរដ្ឋាភិបាលអូស្ត្រាលីកំពុងរកវិធីកែវា។

បើចង់ដឹងថែមទៀត សូមមើលធនធាន ការពន្យល់ស្តង់ដារពិការភាពសំរាប់ការអប់រំ របស់យើង។

# ឥរិយាបថទៅលើពិការភាព

កូនអ្នកគួរតែ:



- ត្រូវបានគេទទួលស្គាល់
- ត្រូវបានគេរាប់បញ្ចូល
- មានចំណែកក្នុងសហគមន៍។

គេក៏ត្រូវប្រព្រឹត្តមកអ្នកបែបនេះដែរ។

បើពិការភាពវាថ្មីដល់គ្រួសារអ្នក អ្នកប្រហែលជាមិនដឹងថានឹងមានអារម្មណ៍យ៉ាងណាទេ។ អ្នកអាចមានអារម្មណ៍ព្រួយ ឬលិចលង់។ អ្នកមានរម្មណ៍យ៉ាងណាក៏ដោយក៏មិនថ្វីទេ។

ប៉ុន្តែគំនិតល្អមួយផងដែរនោះគឺខំស្វែងយល់:

- ថាអ្នកមារម្មណ៍យ៉ាងម៉េចខ្លះ?
- ថាហេតុអ្វីទើបអ្នកមានរម្មណ៍បែបនេះ?
- ថាតើវាមកពីណា?
- ថាតើឥរិយាបថរបស់អ្នកទៅលើពិការភាពគឺអ្វីខ្លះ?

## អ្នកនិងកូនអ្នកមិនឯកោទេ: មនុស្ស1ក្នុង5នាក់នៅអូស្ត្រាលីមានពិការភាព

ពិការភាពមិនមែនជាពាក្យអាក្រក់ទេ។ វាមិនមែនមានន័យថាកូនអ្នកខ្វះអ្វីឡើយ។ ក្មេងគ្រប់រូបរៀននឹងលូតលាស់តាមដំណើររបស់គេ។

មនុស្សមានពិការភាពជួបប្រទះរនាំងក្នុងសង្គម។ រនាំងគឺអ្វីដែលធ្វើអោយពិបាកចូលរួម។

កំណត់សំគាល់: រនាំងមិនមែនជាអ្វីដែលកូនអ្នកបណ្តាលអោយកើតឡើងដោយខ្លួនគេទេ។
តែជាអ្វីមួយក្នុងលោកជុំវិញគេដែលយើងត្រូវផ្លាស់ប្តូរឬដកចេញ។

ឧទាហរណ៍:

នាំងគឺ**ជា**: '೭. កូនខ្ញុំមិនបានទទួលជំនួយអោយទាក់ទងតាមរបៀបដែលជួយគេឡើយ។'

នាំងគឺ**មិនមែន**: 'កូនខ្ញុំនិយាយមិនកើត។'

ជួនកាលមនុស្សជុំវិញយើងអាចគំនិតអវិជ្ជមានអំពីពិការភាព។ ឥរិយាបថអវិជ្ជមានរបស់គេគឺមិនត្រូវទេ។ អ្នកមិនគួរត្រូវគេធ្វើអោយមានអារម្មណ៍ខ្មាសអៀនឬអៀនអន់ឡើយ។

## គោលដៅ

គ្រប់គ្នាមានឥរិយាបថនិងគំនិតខុសគ្នាអំពីពិការភាព។ ប៉ុន្តែយើងធ្វើការឈានឆ្ពោះទៅរកសង្គមដែលប្រសើរជាងនេះជានិច្ច។ នេះគឺសង្គមដែលគោរព រាប់បញ្ចូល និងអោយតំលៃដល់ជនមានពិការភាព។



អ្នកគួរគិតថា អ្នកផងនឹងទទួលនិងរាប់បញ្ចូលកូនរបស់អ្នក។ បើពុំនោះទេ គេកំពុងធ្វើខុសហើយ។ គេប្រហែលជាធ្វើខុសច្បាប់ទៀតផង។

# ជំរើសដល់ការអប់រំកូនអ្នក



នៅប្រទេសអូស្ត្រាលី
កូនអ្នកមានជំរើសខុសៗគ្នាគ្រប់ដំណាក់នៃការអប់រំរបស់គេ។
វាពិបាកនឹងគិតដែរថាកូនអ្នកមានជំរើសអប់រំអ្វីខ្លះ។
សំខាន់គឺត្រូវចាំថា:

**កូនអ្នកគួរមានជំរើសអប់រំគ្រប់យ៉ាង។**

អ្នកផ្ដល់ការអប់រំគួរផ្ដល់កូនរបស់អ្នកនូវឱកាសចុះឈ្មោះរៀនដូចក្មេងដទៃដែរ។ នេះជាច្បាប់នៅប្រទេសអូស្ត្រាលី។
អ្នកផ្ដល់ការអប់រំមិនគួររុញកូនអ្នកទៅផ្លូវអប់រំណាមួយឡើយ ដូចជាអោយទៅសាលារដ្ឋ ឯកជន សាសនា ។ល។

## មុននឹងចុះឈ្មោះកូនរបស់អ្នក

ក្នុងចំណុចណាមួយនៃដំណើរអប់រំនៃកូនអ្នក អ្នកនឹងត្រូវសំរេចចិត្តចុះឈ្មោះកូន។ ពេលធ្វើការសំរេចចិត្ត អ្នកប្រហែលគិតអំពី:

- ទីកន្លែង
- ជំនឿ
- គ្រូសារឬជំនួយ
- ប្រាក់កាស
- តំលៃ
- ការទទួល

សំនួរសំខាន់ៗឯទៀតមានដូចជា:

- តើកូនខ្ញុំនឹងមានសុវត្ថិភាព និងសប្បាយនៅទីនោះឬអត់?
- តើគាត់នឹងទទួលជំនួយដែលគាត់ត្រូវការដើម្បីរៀនសូត្រឬអត់?
- តើគាត់នឹងធ្វើការទាក់ទងគ្នាក្នុងសហគមន៍តាមតំបន់ឬអត់?

អ្នកអាចយល់ដឹងថែមទៀតអំពីការជ្រើសរើសផ្លូវផ្សេងៗក្នុងការអប់រំក្នុងធនធានរបស់យើង: ដំណាក់កាលនិងដំណើរផ្លាស់ប្ដូរ។

## ការអប់រំនិងប្រព័ន្ធបណ្តុះបណ្តាលនៃអូស្ត្រាលី

ប្រព័ន្ធអប់រំអូស្ត្រាលីមានបួនថ្នាក់:

- ការអប់រំក្មេងវ័យដំបូង
- សាលាបឋមសិក្សា
- សាលាមធ្យមសិក្សា
- សាលាឧត្តមសិក្សា។

### ជាន់ថ្នាក់នៃការអប់រំ

| | ប្រភេទនៃអ្នកផ្តល់ការអប់រំ | អាយុក្មេង | ចាំបាច់ ឬ ជំរើស |
|---|---|---|---|
| 1 | ការអប់រំក្មេងវ័យដំបូង ឧ. មត្តេយ្យ សាលានិងសាលាដំបូង | ជាទូទៅ 3–5ឆ្នាំ | ជាជំរើសប៉ុន្តែលើកទឹកចិត្តអោយចូលចាប់ពីអាយុ 4 ឆ្នាំឡើងទៅ |
| 2 | សាលាបឋមសិក្សា | ជាទូទៅ 5–12ឆ្នាំ | ចាំបាច់ – កុមារគ្រប់រូបត្រូវទៅសាលាពីអាយុ 6 ឆ្នាំឡើងទៅ |
| 3 | សាលាមធ្យមសិក្សា | ជាទូទៅ 12–18ឆ្នាំ | ចាំបាច់លុះដល់អាយុ 16, 17 ឬ 18 ឆ្នាំ ស្រេចលើរដ្ឋឬអនុរដ្ឋ ដែលអ្នកនៅ |
| 4 | ឧត្តមសិក្សា ឧ. សាលាអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (រួមទាំង TAFE), ការហ្វឹកហ្វឺននៅកន្លែងធ្វើការ សាលាជាន់ខ្ពស់ (រួមទាំងសកលវិទ្យាល័យ) | ជាទូទៅ 15ឆ្នាំឡើងទៅ (អាចរួមជាមួយសាលាមធ្យមសិក្សា) | ចាំបាច់ |

## ប្រភេទសាលា

អូស្ត្រាលីមានសាលាពីរប្រភេទ គឺសាលារដ្ឋនិងសាលាក្រៅពីរដ្ឋ។

សាលារដ្ឋត្រូវដឹកនាំដោយរដ្ឋនិងរដ្ឋាភិបាលអនុរដ្ឋ ហើយជាទូទៅមិនយកប្រាក់កាសទេ។

សាលាក្រៅពីរដ្ឋត្រូវដឹកនាំដោយអង្គការ។ ឧទារណ៍ មានសាលាសាសនានិងសាលាឯកជន។ សាលាទាំងនេះយកប្រាក់កាស។

មានប្រាក់មូលនិធិសំរាប់គ្រប់សាលាសំរាប់ផ្តល់**ការកែសំរួលសមហេតុផល**ដើម្បីជួយគាំទ្រសិស្សដែលមានពិការភាពអោយចូលរៀន។

**គ្រប់**សិស្សដែលមានពិការភាពមានសិទ្ធិទៅសាលាប្រចាំតំបន់ ឬមណ្ឌលរបស់គេ។
កន្លែងខ្លះបើកសំរាប់តែសិស្សដែលមានពិការភាព។
អ្នកអាចស៊ើបរកការទាំងនេះតាមវែបសៃត៍នៃក្រសួងអប់រំក្នុងរដ្ឋឬអនុរដ្ឋរបស់អ្នក។

# ពេលកូនអ្នកចុះឈ្មោះហើយ

កូនអ្នកគួរត្រូវបានគាំទ្រអោយទទួលជំរើសគ្រប់យ៉ាងបន្ទាប់ពីបានចុះឈ្មោះចូលរៀនហើយ។ ជំរើសទាំងនេះមានរួមទាំងថ្នាក់រៀន សកម្មភាព មេរៀន និងការផ្តល់សញ្ញាប័ត្រផ្សេងៗគ្នា។

ដូចមិត្តស្រករគ្នារបស់គេដែរ កូនអ្នកគួរតែអាច:



ចុះឈ្មោះហើយគេទទួលអោយចូលក្នុងស្ថាប័នអប់រំ



ចូលរួមក្នុងគ្រប់មេរៀនអប់រំ ឬកម្មវិធីរបស់គេ



រួមចំណែកក្នុងបទពិសោធន៍រៀនសូត្រ



រៀនក្នុងបរិស្ថានដ៏សុខសាន្ត ផុតពីការរើសអើង ការយាយី និងការធ្វើបាប



ប្រើសេវាកម្មគាំទ្រ ឧ. អ្នកផ្តល់ឱវាទប្រចាំសាលា

កំណត់សំគាល់: អ្នកអាចស្វែងយល់ថែមទៀតអំពីការយាយីនិងការធ្វើបាបក្នុងធនធានរបស់យើង: ពន្យល់ស្តង់ដារពិការភាពសំរាប់ការអប់រំ។

សិស្សរាល់រូបមានការជ្រើសរើសនិងឱកាស។ ក៏គួរតែដូចគ្នាឬស្រដៀងគ្នាសំរាប់សិស្សដែលមានពិការភាពដែរ។ នេះមិនមែនបានដល់តែថ្នាក់រៀនទេ គឺបានដល់ប្រការដូចជាការបោះតង់សាលា និងការលែងកំសាន្តពេលឈប់សំរាក។

## រកជំនួយដែលកូនអ្នកត្រូវការដើម្បីចូលរួម និងចូលរៀន

នៅពេលអ្នកចាប់ផ្តើមគិតអំពីពិការភាពនិងការអប់រំ អ្នកអាចសួរខ្លួនឯងថា: តើកូនអ្នកត្រូវការជំនួយក្នុងផ្នែកណាមួយទាំងនេះឬទេ?



បើគេត្រូវការជំនួយ តើគេបានទទួលជំនួយនេះឬអត់ឥឡូវនេះ? បើអត់ទេ សូមទាក់ទងសាលាឬមណ្ឌលហើយសូមណាត់ជួប។ អ្នកនិងសាលាអាចលៃលកគ្នាពិគ្រោះជំរើសរបស់កូនអ្នក។

តើគេទទួលជំនួយគាំទ្រសំរាប់ការនេះហើយ តែត្រូវការថែមទៀតឬ? បើដូច្នោះ សូមទាក់ទងសាលាឬមណ្ឌលដើម្បីពិគ្រោះពីជំនួយគាំទ្របន្ថែម។

បើកូនអ្នកមិនបានទទួលជំនួយដែលគាត់ត្រូវការ នោះអ្នកមានសិទ្ធិសូមអោយមានការផ្លាស់ប្តូរ។ ទាំងនេះហៅថា**ការកែសំរួលសមហេតុផល។**
ក្មេងគ្រប់រូបដែលមានពិការភាពមានសិទ្ធិដល់ការកែសំរួលទាំងនេះ ដើម្បីអោយគេបានរៀន ហើយចូលរួម។

## និយមន័យ: ការកែសំរួលសមហេតុផល

**ការកែសំរួល**ជាការផ្លាស់ប្តូរ ឬការសំរប។
ការទាំងនេះជាអំពើដែលជួយក្មេងៗចូលរួមជាមួយមិត្តស្រករគ្នារបស់គេ។ ពួកគេអាចជា:

- មនុស្សម្នា (ឧ. បុគ្គលិកជំនួយ)
- ឧបករណ៍ (ឧ. គ្រឿងអាន)
- ការផ្លាស់ប្តូរដល់របៀបធ្វើអ្វីមួយ (ឧ. ការឈប់សំរាក)។

តួនាទីរបស់អ្នកផ្តល់ការអប់រំគឺត្រូវចាត់ចែង ហើយផ្តល់ប្រាក់មូលនិធិដល់ការកែសំរួល លើកលែងវាបណ្តាលអោយមានភាពលំបាកហួសហេតុផលដល់អ្នកផ្តល់។

អ្វីដែល**សមហេតុផល**នឹងខុសគ្នាគ្រប់ករណី។ ប៉ុន្តែអ្នកផ្ដល់ការអប់រំគួរពិចារណាចំណុចដូចជា:

- តើអ្នកនិងកូនអ្នកចង់បានអ្វី?
- តើពិការភាពរបស់កូនអ្នកមានផលវិបត្តិយ៉ាងណាខ្លះដល់គាត់?
- តើការផ្លាស់ប្ដូរនឹងប៉ះពាល់យ៉ាងណាខ្លះដល់កូនអ្នក និងដល់សមត្ថភាពចូលរួមរៀនយ៉ាងណាខ្លះ?
- តើការផ្លាស់ប្ដូរនឹងប៉ះពាល់ដល់បុគ្គលិកនិងសិស្សឯទៀតយ៉ាងណាខ្លះ?
- តើការចំណាយនិងផលប្រយោជន៍នៃការផ្លាស់ប្ដូរមានអ្វីខ្លះ?
- តើអ្នកផ្ដល់អាចទទួលប្រាក់កាសឬជំនួយផ្សេងៗទៀតមកជួយធ្វើការផ្លាស់ប្ដូរបានឬអត់ (ឧ.មូលនិធិរដ្ឋ)?

ជាទូទៅ អ្នកផ្ដល់ការអប់រំត្រូវធ្វើការកែសំរួលសមហេតុផល។ ពេលតែមួយគត់ដែលគេចាំបាច់ធ្វើគឺនៅពេលការផ្លាស់ប្ដូរនឹងបណ្ដាលអោយមាន'ភាពលំបាកហួសហេតុផល'។ នេះមានន័យថាជាភាពលំបាកដែលធ្ងន់ធ្ងរពេកក្រៃលុះអនុវត្តមិនបាន។

អ្នកដែលត្រូវបង្ហាញថាការផ្លាស់ប្ដូរនឹងមានភាពលំបាកហួសហេតុផលគឺអ្នកផ្ដល់។ អ្នកមិនបាច់បង្ហាញអ្វីឡើយ។



ឧទាហរណ៍នៃការកែសំរួលសមហេតុផលមានដូចជា:

- ការសំរាក/បន្ទប់ទឹក/ការសំរាកញ៉ាំអាហារសំរន់
- ជំនួយថ្នាក់រៀន
- អ្នកបកប្រែផ្ទាល់មាត់ Auslan
- គ្រូដែលអនុញ្ញាតអោយមានអកប្បកិរិយាម្យ៉ាងក្នុងថ្នាក់
- ពេលផុតកំណត់ដែលផ្លាស់ប្ដូរបាន/ការពន្យារពេល
- វេលាអានបន្ថែម
- ផ្លូវជំរាល
- ឧបករណ៍សំរាប់កត់
- ជំនួយដល់ការទាក់ទង
- កៅអីដែលបង្កើនឬបន្ថយកំពស់បាន។

ឬកូនអ្នកប្រហែលត្រូវការអ្វីផ្សេងទៀត។

## ឱវាទសំរាប់មាតាបិតានិងអ្នកថែរក្សា

ក្នុងឋានៈជាមាតាបិតាឬអ្នកថែរក្សាកូនដែលមានពិការភាព អ្នកៈ

- មិនគួរត្រូវបានគេប្រព្រឹត្តមកខុសគេដោយព្រោះតែពិការភាពរបស់កូនអ្នក
- គួរមានចំណែកក្នុងការសំរេចចិត្តដែលប៉ះពាល់ដល់កូនអ្នក
- គួរបញ្ចេញគំនិតបានបើមានអ្វីដែលមិនត្រឹមត្រូវ
- គួរមានជំរើសលើទីកន្លែងកូនអ្នកទៅរៀន

បើចង់ដឹងថែមទៀត សូមមើលធនធានរបស់យើង: ពន្យល់ស្ដង់ដារពិការភាពសំរាប់ការអប់រំ។

# គោលដៅសំរាប់ការអប់រំរបស់កូនអ្នក

អ្នកអាចគិតថា ការអប់រំរបស់កូនអ្នកជាការធ្វើដំណើរមួយ។ មានផ្លូវច្រើនដែលគេអាចទៅបាន។

ប៉ុន្តែមុននឹងអ្នកជ្រើសរើសផ្លូវណាមួយ យកល្អគួរគិតអំពី:

- អ្វីដែលមានអ្នកចង់បានសំរាប់អនាគតកូនអ្នក
- បទពិសោធន៍អ្វីខ្លះដែលអ្នកចង់អោយគាត់មានតាមដំណើរនោះ។

## សំនួរដើម្បីសួរខ្លួនឯង

- តើខ្ញុំចង់បានអ្វីសំរាប់ការអប់រំកូនខ្ញុំ ? (តើកូនខ្ញុំចង់បានអ្វីពីការអប់រំរបស់គាត់ ?)

- តើមានរនាំងអ្វីខ្លះ (បើមាន) មករារាំងមិនអោយការនេះកើតឡើង? (តើមានឥរិយាបថអវិជ្ជមានឬទេ ? តើឥឡូវអ្វីៗស្រួលបួលហើយឬ ?)

- តើខ្ញុំចង់អោយអ្នកផ្តល់ការអប់រំធ្វើអ្វីដើម្បីលើកឧបសគ្គទាំងនេះចេញ ? (ផ្តល់ឧបករណ៍ ? ជួយខាងការសិក្សា ? ជួយដល់រាងកាយ ? អ្វីផ្សេងទៀត ?)

- តើគេប្រាប់ខ្ញុំអ្វីខ្លះ ? (តើវាត្រូវនឹងអ្វីដែលខ្ញុំដឹងអំពីសិទ្ធិរបស់កូនខ្ញុំឬទេ ? តើអ្នកផ្តល់កំពុងជំរុញខ្ញុំឆ្ពោះទៅផ្លូវមួយ ឬជំរើសមួយឬ ?)

- តើអ្នកណាសំរេចចិត្តថាកូនខ្ញុំត្រូវការជំនួយគាំទ្រអ្វីនោះ ? (តើគេសំរេចចិត្តដោយរបៀបណា ? តើខ្ញុំបានចូលរួមក្នុងការសំរេចនេះឬអត់ ?)

អ្នកគួរ**អោយកូនអ្នកចូលរួម**ក្នុងការសំរេចចិត្តទាំងអស់អំពីការអប់រំរបស់គាត់។ អ្នកធ្វើយ៉ាងណានោះគឺស្រេចទៅលើអាយុនិងតំរូវការនិងចំណូលចិត្តរបស់គាត់។

ចូរចាំថាៈ

| | |
|---|---|
| ជំរើសមិនគួរបិតដល់កូនអ្នកទេ | • កូនអ្នកមិនត្រូវការរោគវិនិច្ឆ័យសរាប់ដាក់ពាក្យសុំទៅ DDA ឬ DSE ទេ។ បើគិតថាក្មេងនោះត្រូវរបស់នៅដោយមានពិការភាព នោះអាចប្រើ DDA និង DSE បាន។<br>• អ្នកគួរចុះឈ្មោះកូនអ្នកចូលរៀនស្ថិតលើមូលដ្ឋានដូចមិត្តមិនពិការរបស់កូនអ្នកដែរ (បើត្រូវអាយុ ទីកន្លែង និងកត្តាផ្សេងៗទៀត)។<br>• គ្រប់អ្នកផ្តល់ការអប់រំមានកាតព្វកិច្ចគាំទ្រកូនអ្នក។ គេគួរខិតខំអោយបានសមគួរដើម្បីជួយអោយបានសំរេច។<br>• ការគាំទ្រដែលកូនអ្នកត្រូវការអាចជារឿងថ្មីសំរាប់បុគ្គលិក តែគេគួរស្តាប់ ស្វែងរករៀន និងសាកល្បងអ្វីមួយដើម្បីរកវិធីជួយអោយបានសំរេច។ នេះជាមុខងាររបស់គេ។ |
| អ្នកមិនបាច់ផ្តល់ចំឡើយទាំងអស់ទេ | • អ្នកយល់កូនអ្នកនិងសេចក្តីត្រូវការរបស់គាត់។ អ្នកអប់រំនៅទីនោះចាំជួយគាំទ្រកូនអ្នកអោយរៀន។ អ្នកអាចពិគ្រោះគ្នាបាន។<br>• អ្នកផ្តល់ការអប់រំត្រូវជួយក្មេងមានពិការភាព។ វាមិនគួរអាស្រ័យទៅលើ 'កំរិត' ឬ 'ភាពធ្ងន់ធ្ងរ' នៃពិការភាពរបស់កូនអ្នកឡើយ។<br>• មានធនធានដែលអ្នកអប់រំអាចប្រើដើម្បីសំរេចសេចក្តីត្រូវការរបស់កូនអ្នក។ ឧ. ឧបករណ៍ អែព អ្នកធ្វើការជំនួយ ការហ្វឹកហ្វឺន ។ល។<br>• ទំនួលខុសត្រូវរបស់អ្នកផ្តល់ការអប់រំគឺត្រូវផ្តល់ប្រាក់មូលនិធិ ហើយចាត់ចែងអោយមានការកែសំរួល វាមិនមែនមាតាបិតាឬអ្នកថែរក្សាទេ។ នេះគឺពិត លុះត្រាណាគេអាចបង្ហាញនូវភាពលំបាកហួសហេតុផល។ (សូមមើលនិយមន័យនៃ 'ការកែសំរួលសមហេតុផល' នៅទំព័រ 11).<br>• អ្នកមិនចាំបាច់ដឹងគ្រប់ទាំងអស់អំពីពិការភាពរបស់កូនអ្នកក្នុងពេលជាមួយគ្នានោះទេ។ អ្នកនឹងដឹងមិនយូរមិនឆាប់។ សេចក្តីត្រូវការរបស់កូនអ្នកអាចផ្លាស់ប្តូរ។ អ្នកអាចសុំជំនួយគាំទ្រផ្សេងទៀតនៅពេលក្រោយបានជានិច្ច។ |

# កន្លែងទទួលការគាំទ្រនិងព័ត៌មាន

## ជំនួយលើការទាក់ទង

| សេវាកម្មបកប្រែភាសានិងបកប្រែផ្ទាល់មាត់ | សេវាកម្មបញ្ជូនតប្រចាំជាតិ | សេវាកម្មបកប្រែឥតគិតថ្លៃ |
|---|---|---|
| គេអាចជួយបានបើអ្នកមិនចេះនិយាយភាសាអង់គ្លេស។<br>• ទូរស័ព្ទ: **131 450**<br>• វែបសៃត៍: https://www.tisnational.gov.au | គេអាចជួយបានបើអ្នកត្រូវការសំឡេងទៅសារ សារទៅសំឡេង Auslan ទៅអង់គ្លេស ឬអង់គ្លេសទៅAuslan ។<br>• ទូរស័ព្ទ: **1300 555 727** (និយាយនិងស្តាប់)<br>• វែបសៃត៍: https://www.accesshub.gov.au | គេអាចបកប្រែឯកសារសំខាន់ផ្ទាល់ខ្លួន។<br>សូមទៅមើលវែបសៃត៍ដើម្បីអោយបានដឹងថានរណាអាចប្រើសេវាកម្មនេះបាន។<br>• ទូរស័ព្ទ: **1800 962 100**<br>• វែបសៃត៍: https://translating.homeaffairs.gov.au |

### ការចិញ្ចឹមកូន ការមើលថែរក្សា និងជំនួយគាំទ្រពិការភាព

អ្នកគួរស្វែងរកជំនួយគាំទ្រនៅពេលដែលអ្នកគិតថាអ្នកប្រហែលត្រូវការវា។
អ្នកមិនចាំបាច់ចាំដល់មានវិបត្តិទេមុននឹងសួររកជំនួយ។

- បណ្តាញចិញ្ចឹមកូន (https://www.raisingchildren.net.au) – មជ្ឈមណ្ឌលនៃព័ត៌មានអំពីការចិញ្ចឹមកូន និងធនធាននានា
- បណ្តាញចិញ្ចឹមកូន (https://www.raisingchildren.net.au/grown-ups/ services-support/about-services-support/helplines) - បញ្ជីលេខទូរស័ព្ទជំនួយសំរាប់មាតាបិតានិងអ្នកថែរក្សា
- ច្រកផ្លូវសំរាប់អ្នកថែរក្សា (https://www.carergateway.gov.au) – មជ្ឈមណ្ឌលជំនួយសំរាប់អ្នកថែរក្សា
- បណ្តាញគាំទ្រអោយពិការភាពអូស្ត្រាលី (https://www.dana.org.au/find-an-advocate) – បញ្ជីអង្គការភាពគាំទ្រ
- មជ្ឈមណ្ឌលពិការភាពអូស្ត្រាលី (https://www.disabilityaustraliahub.com.au) – បញ្ជីអង្គារពិការភាព
- ច្រកផ្លូវពិការភាព (https://www.disabilitygateway.gov.au) – តំណទៅសេវាកម្ម ការអប់រំ និងធនធានអំពីភាពគាំទ្រ

## ព័ត៌មានអំពីប្រព័ន្ធអប់រំនៃប្រទេសអូស្ត្រាលី

- ការតាំងទីលំនៅនៅប្រទេសអូស្ត្រាលី (https://immi.homeaffairs.gov.au/settling-in-australia/ settle-in-australia/key-settlement-topics/education-and-training)
- ក្រសួងអប់រំរដ្ឋាភិបាលអូស្ត្រាលី (https://www.education. gov.au)
- គំរោងធានារ៉ាប់រងពិការភាពជាតិ (NDIS) (https://ourguidelines.ndis.gov. au/how-ndis-supports-work-menu/mainstream-and-community-supports/ who-responsible-supports-you-need/school-education) – NDIS ផ្តល់ប្រាក់មូលនិធិដល់សេវាកម្មនិងជំនួយគាំទ្រពិការភាព។

## ធនធានព័ត៌មានឯទៀតក្នុងសេរីនេះ

- ការពន្យល់ស្តង់ដារពិការភាពសំរាប់ការអប់រំ (https://www.education. gov.au/disability-standards-education-2005/information-resources- students-disability-and-their-caregivers) – ធនធានដើម្បីជួយអ្នកអោយដឹងថែមទៀតអំពីសិទ្ធិកូនអ្នកក្នុងការអប់រំ។
- ដំណាក់កាលនិងការដំណើរផ្លាស់ប្តូរ (https://www.education.gov.au/km/disability-standards-education-2005/students/khmer/milestones) – ធនធានជួយអ្នកអោយជួយគាំទ្រកូនអ្នកក្នុងរយៈពេលមានការផ្លាស់ប្តូរក្នុងការអប់រំ។
- ធនធានដើម្បីជួយគាំទ្រអ្នកនិងកូនអ្នកអោយសំរេចចិត្ត ហើយសុំស្នើសំរាប់សេចក្តីត្រូវការរបស់គាត់ៈ
  - ការថែរក្សានិងការអប់រំកុមារភាពវ័យដំបូង – គាំទ្រអោយកូនអ្នក(https://www.education.gov.au/disability-standards-education-2005/resources/advocating-your-child)
  - បឋមសិក្សា – គាំទ្រជាមួយកូនអ្នក និងគាំទ្រសំរាប់កូនអ្នកៈ បឋមសិក្សា (https://www.education.gov.au/disability-standards-education-2005/ students/english/advocating)
  - មធ្យមសិក្សា (និងការអប់រំនិងហ្វឹកហាត់បន្ថែម) – ធ្វើការជាមួយគ្នាៈ ឆ្លងកាត់សាលាមធ្យមសិក្សា (https://www.education.gov. au/disability-standards-education-2005/resources/working-together) និងស្តង់ដារពិការភាពសំរាប់ការអប់រំក្នុងការអនុវត្តៈ គំរោងចាត់ការ (https://www.education.gov.au/disability-standards-education-2005/ students/english/dse-in-practice)
- ជំហានជំរាបពីបារម្ភនិងការដោះស្រាយតំអូញជាមួយសាលារបស់អ្នក – ធនធានដើម្បីជួយអ្នកការពារ ស៊ើបសួរ និងដោះស្រាយបារម្ភទាំងឡាយជាមួយសាលារបស់កូនអ្នក

https://www.education.gov.au/disability-standards-education-2005/information-resources-students-disability-and-their-caregivers